# សេចក្តីប្រកាសរួមស្តីអំពីការបើកឱ្យដំណើរការការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ដោយឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាល និងលោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាល

ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកឲ្យ ដំណើរការក្នុងសប្តាហ៍នេះហើយ ចំណែកក្រុមការងាររួមក៏កំពុងចាប់ផ្តើមការងាររបស់ពួកគេដែរ ។ យើងខ្ញុំមានសេចក្តីរីករាយណាស់ក្នុងការទទួលស្វាគមន៍អ្នកសារព័ត៌មានជាលើកដំបូងនៅក្នុងទីតាំងអគារធ្វើការថ្មីរបស់យើង រួមមានអគារការិយាល័យមួយនិងសាលសវនាការមួយដែលប្រកបទៅដោយទីធ្លាធំទូលាយ ហើយឥឡូវនេះនឹងត្រូវបានដាក់ឲ្យប្រើប្រាស់ជាអគារធ្វើការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ យើងអាចនិយាយបានយ៉ាងច្បាស់ថា យើងបានឆ្លងពីដំណាក់កាលរៀបចំ ហើយឈានចូលដល់ការបង្កើតជាក់ស្តែងនូវអង្គជំនុំ ជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា ឬអ៊ី.ស៊ី.ស៊ី.ស៊ី. ។

ឆ្លៀតក្នុងឱកាសនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់អំណោយទាំងអស់ ទាំងចំពោះអ្នកដែលបានចូលរួមវិភាគទានជាថវិកាតាមរយៈអង្គការសហប្រជាជាតិ និងទាំងចំពោះអ្នកដែលបានចូលរួមវិភាគទានជាថវិកាតាមរយៈភាគីកម្ពុជា ដែលនៅខ្វះខាតប្រមាណ៩.៦លានដុល្លារទៀត ។ យើងខ្ញុំមានការជឿជាក់ថា មូលនិធិដែលនៅសេសសល់នឹងត្រូវបានធានាក្នុងពេលឆាប់ៗនេះ ហើយយើងខ្ញុំសូមធ្វើការអំពាវនាវម្តងទៀតសម្រាប់ការផ្តល់ជំនួយផ្នែកវិភាគទាននេះ ។

យើងខ្ញុំមិនបណ្តោយឲ្យកង្វះខាតនាពេលបច្ចុប្បន្នរាំងស្ទះដល់ការបើកឲ្យដំណើរការរបស់ការិយាល័យរដ្ឋបាលនិងផ្តើមការងាររបស់ក្រុមការងាររួមសម្រាប់ការិយាល័យរដ្ឋបាលនេះទេ ។ ដៃគូរបស់យើងខ្ញុំមកពីអង្គការសហប្រជាជាតិដែលដឹកនាំដោយលោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាល បានចាប់ផ្តើមធ្វើដំណើរមកដល់ទីក្រុងភ្នំពេញដើម្បីទទួលការងាររបស់ពួកគេនៅ អ៊ី.ស៊ី.ស៊ី.ស៊ី នេះ ។ ចំពោះផ្នែកច្បាប់និងតុលាការដំណាក់កាលចុងក្រោយនៃ ការតែងតាំងចៅក្រមជាតិនិងអន្តរជាតិ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត កំពុងតែដំណើរការ ហើយយើងខ្ញុំរំពឹងទុកថានឹងអាចប្រកាសឈ្មោះរបស់ពួកគេក្នុងពេលដ៏ឆាប់ខាងមុខ នេះ ។ កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តនូវសេចក្តីសម្រេចមួយក្រោមការផ្តល់អនុសាសន៍ពីអគ្គលេខាធិការដែលសម្រេចថាចៅក្រមអន្តរជាតិ សហព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតអន្តរជាតិទាំងអស់ នឹងត្រូវចាត់ទុកជាមន្ត្រីរបស់អង្គការសហប្រជាជាតិ សម្រាប់បំពេញលើលក្ខខណ្ឌការងាររបស់ពួកគេ ហើយអនុម័តផ្តល់នូវនីតិសម្បទាឲ្យពួកគេដោយយោងលើលក្ខខណ្ឌនេះ ។

ចំពោះភាគីអង្គការសហប្រជាជាតិ មន្ត្រីតុលាការដែលត្រូវបានជ្រើសរើសនោះកំពុងត្រូវបានត្រួតពិនិត្យសុខភាព ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានរំពឹងទុកថា នឹងផ្តល់បញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំងដល់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការជ្រើសរើសចុងក្រោយ និងតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ យើងខ្ញុំសង្ឃឹមថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងប្រកាសក្នុងពេលជាមួយគ្នានូវឈ្មោះមន្ត្រីតុលាការកម្ពុជាដែលនឹងត្រូវតែងតាំង ។

ការត្រៀមលក្ខណៈផ្សេងៗទៀតក៏កំពុងតែដំណើរការដែរ ដូចជាការរៀបចំបោះពុម្ពឡើងវិញនូវកូនសៀវភៅការណែនាំស្តីពីការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម សម្រាប់ការផ្សព្វផ្សាយទូទាំងប្រទេស ការចងក្រងប្រមូលឯកសារច្បាប់ជាមូលដ្ឋានចំនួនជាង១០០ជាភាសាផ្លូវការនៅក្នុងតុលាការ និងកម្មវិធីផ្សព្វផ្សាយព័ត៌មានតាមតំបន់ (បានទទួលការឧបត្ថម្ភពីរដ្ឋាភិបាលប្រទេសអូស្ត្រាលីនិងប្រទេសន័រវេស) ។ យើងខ្ញុំដឹងថាភារកិច្ចនៅចំពោះមុខរបស់បុគ្គលិក និងមន្ត្រីតុលាការទាំងអស់ជាកិច្ចការមួយសំខាន់ដែលចាំបាច់ត្រូវប្រើឲ្យអស់លទ្ធភាពនូវបទពិសោធន៍ ការប្រឹងប្រែងនិងភាពអត់ធ្មត់ ប៉ុន្តែយើងខ្ញុំសន្យាថានឹងខិតខំឲ្យអស់ពីសមត្ថភាពដើម្បីទទួលខុសត្រូវនូវរាល់កាតព្វកិច្ចដែលបានប្រគល់ឲ្យក្នុងន័យសបញ្ជាក់ថា ភាពយឺតយូរក្នុងការរកយុត្តិធម៌នឹងមិនមានន័យថាមិនមានយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាដែលបានទន្ទឹងរង់ចាំអស់ពេលជាយូរមកហើយនោះទេ ។

**ធ្វើនៅភូមិកន្ទោក ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៦, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**